# សិក្ខាសាលាជាតិ
## ស្តីពី
## ការពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារទស្សនទានសម្រាប់រៀបចំកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិជំណាក់កាលទី២
## (២០២១ - ២០៣០)

ថ្ងៃ០៦រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០ សាលប្រជុំក្រសួងមហាផ្ទៃ (អគារ ទ)

## សុន្ទរកថាបើក
## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ**
- **ឯកឧត្តមប្រធានក្រុមប្រឹក្សា ឯកឧត្តម លោកជំទាវអភិបាលរាជធានី ខេត្ត**
- **លោក លោកស្រីប្រធានក្រុមប្រឹក្សា អភិបាលក្រុង ស្រុក ខណ្ឌ**
- **លោក លោកស្រីតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកានៃសិក្ខាសាលាជាតិ ជាទីមេត្រី**!

ជាបឋម ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាម គ.ជ.អ.ប. ខ្ញុំសូមសម្តែងនូវការស្វាគមន៍ចំពោះវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តម លោកជំទាវ លោក លោកស្រីជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិ តំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាដែលបានអញ្ជើញចូលរួមក្នុងសិក្ខាសាលាជាតិស្តីពី "**ការពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារទស្សនទានសម្រាប់រៀបចំកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិជំណាក់កាលទី២**" ដ៏មានសារៈសំខាន់នាថ្ងៃនេះ។

ក្នុងនាមរាជរដ្ឋាភិបាល ក្នុងនាម គ.ជ.អ.ប. និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត និងថ្លែងនូវការកោតសរសើរចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីនៃក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានផ្តល់ការគាំទ្រ និងចូលរួមអនុវត្តយ៉ាងសកម្មក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងរយៈពេល២ទសវត្សរ៍កន្លងមកនេះ ដោយបានជំរុញឱ្យកំណែទម្រង់នេះមានការវិវឌ្ឍជាជំហានៗ ស្របតាមដំណាក់កាលនីមួយៗដែលបានកំណត់ក្នុងកម្មវិធី

នយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ព្រមទាំងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំដំបូង (២០១០-២០២០)។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ ក្នុងនាមរាជរដ្ឋាភិបាល ក្នុងនាម គ.ជ.អ.ប. និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំក៏សូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីនៃក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានរួមសហការគ្នារៀបចំ និងអនុវត្តនូវកិច្ចការចាំបាច់ និងអាទិភាពនានាក្នុងការប្រយុទ្ធប្រឆាំងនឹងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ដ៏កាចសាហាវផង និងការជួយសង្គ្រោះប្រជាពលរដ្ឋដែលទទួលរងគ្រោះដោយគ្រោះធម្មជាតិនានា ជាពិសេសគ្រោះទឹកជំនន់ដែលបានកើតឡើងនៅតាមបណ្តារាជធានី ខេត្តមួយចំនួនក្នុងព្រះរាជាណាចក្រកម្ពុជានាពេល ថ្មីៗកន្លងមកនេះ ដោយទទួលបានលទ្ធផលគួរជាទីមោទនៈ ព្រមទាំងរក្សាបាននូវនិរន្តរភាពនៃការបំពេញការងារលើគ្រប់វិស័យ។

ទន្ទឹមនេះ បើទោះបីជាក្នុងឆ្នាំ២០២០នេះ ពិភពលោកយើងទាំងមូលបាន និងកំពុងទទួលរងនូវការគំរាមកំហែងធ្ងន់ៗពីគ្រោះមហន្តរាយនានា ដូចជាការផ្ទុះឡើងនូវជំងឺកូវីដ-១៩ដ៏កាចសាហាវ និងការប្រែប្រួលអាកាសធាតុដែលបណ្តាលឱ្យកើតឡើងនូវគ្រោះរាំងស្ងួត និងទឹកជំនន់ដោយថាហេតុនានា ព្រមទាំងការទទួលរងនូវផលប៉ះពាល់ពីជម្លោះនៃការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច និងនយោបាយរវាងប្រទេសមហាអំណាចមួយចំនួនដែលបាន និងកំពុងបង្កឱ្យមានហានិភ័យយ៉ាងធ្ងន់ធ្ងរទាំងទៅលើអាយុជីវិតរបស់មនុស្សលោក និងសេដ្ឋកិច្ចនៃបណ្តាប្រទេសនានាក៏ដោយ ក៏ក្រោមការដឹកនាំ ប្រកបដោយភាពឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយក រដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រួមជាមួយនឹងការគាំទ្រ និងការចូលរួមយ៉ាងសកម្ម របស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីនៃក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធនានាបានធ្វើឱ្យកម្ពុជាយើងគ្រប់គ្រងនូវហានិភ័យទាំងនេះបានយ៉ាងល្អប្រសើរ រក្សា ធានាបាននូវសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងរក្សាបាននូវលំនឹងសេដ្ឋកិច្ច និងសង្គមទូទាំងប្រទេស។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី** !

ផ្អែកលើមូលដ្ឋានគ្រឹះដ៏រឹងមាំនៃសុខសន្តិភាព និងស្ថេរភាពនយោបាយ ក្រោមការដឹកនាំប្រកបដោយឆន្ទៈនយោបាយដ៏ច្បាស់លាស់ និងមុះមុតរបស់រាជរដ្ឋាភិបាលដែលមាន **សម្តេចតេជោ ហ៊ុន សែន** ជាប្រមុខ បានជំរុញឱ្យការរៀបចំ និងអនុវត្តគោលនយោបាយកំណែទម្រង់នានា រួមទាំងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដំណើរការយ៉ាងល្អប្រសើរ និងសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន។ គិតមកទល់ពេលនេះ យើងបានអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការអស់រយៈពេល២ទសវត្សរ៍កន្លងមកហើយ បើគិតពីពេលដែល

យើងបានចាប់ផ្ដើមដំណាក់កាល ដំបូងនៃការធ្វើកំណែទម្រង់វិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់នាឆ្នាំ២០០១។ ដោយឡែក បើពិនិត្យលើ ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំដំបូង គិតចាប់ពីឆ្នាំ២០១០មករហូតមកដល់ចុងឆ្នាំ២០២នេះ នោះយើងបានប្រើប្រាស់ពេលវេលាអស់១០ឆ្នាំហើយ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមគូសបញ្ជាក់ជូននូវសមិទ្ធផលសំខាន់ៗដែលយើងសម្រេចបាន និងបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលយើងត្រូវរួមគ្នាបន្តដោះស្រាយ ដូចខាងក្រោម៖

**១. ការរៀបចំក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

ក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌគោលនយោបាយសំខាន់ៗសម្រាប់ផ្តល់ជាមូលដ្ឋានគតិយុត្តសម្រាប់ការរៀបចំប្រព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ អនុម័ត និងដាក់ឱ្យអនុវត្តទៅតាមដំណាក់កាលនីមួយៗជាអាទិ៍រួមមាន៖ ច្បាប់រៀបចំអង្គការ ចំនួន០៤ រួមមាន ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ត្រូវបានរៀបចំ និងអនុម័តនាឆ្នាំ២០០១ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុម ប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌត្រូវបានរៀបចំ និងអនុម័តនាឆ្នាំ២០០៨ ព្រមទាំងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវបានរៀបចំ និងអនុម័តនាឆ្នាំ២០០៥ដែលជាឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់កំណត់នូវចក្ខុវិស័យ និងគោលការណ៍គ្រឹះសម្រាប់រៀបចំដំណើរការកែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ។ ដើម្បីធានាដល់ការអនុវត្តនូវក្របខ័ណ្ឌច្បាប់ និងគោលនយោបាយខាងលើនេះ បណ្តាលិខិតបទដ្ឋានគតិយុត្តដែលតម្រូវដោយច្បាប់រៀបចំអង្គការ និងឯកសារណែនាំបច្ចេកទេសនានាប្រមាណជាង៤០០ប្រភេទត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តពាក់ព័ន្ធនឹងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ ធនធាន ផែនការ របៀបរបបការងារ គោលការណ៍ នីតិវិធី និងស្តង់ដានៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

**២. ការរៀបចំស្ថាប័ននៅថ្នាក់ក្រោមជាតិ**

មូលដ្ឋានគ្រឹះសំខាន់ៗសម្រាប់ធានាដល់ការលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវាសាធារណៈ និងការបង្កើនល្បឿននៃការអភិវឌ្ឍមូលដ្ឋាន ស្របតាមគោលការណ៍ប្រជាធិបតេយ្យ និងវិមជ្ឈការត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ក្នុងនោះរួមមាន៖

- ការបង្កើតឡើងនូវក្រុមប្រឹក្សាតាមប្រភេទនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ តាមរយៈការបោះឆ្នោតសកល និងអសកលដែលបានចាប់ផ្តើមជាដំបូងដោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅទូទាំងប្រទេសនាឆ្នាំ២០០២ និងការចាប់ផ្តើមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេសនាឆ្នាំ២០០៩។ ការបោះឆ្នោតជ្រើសរើសក្រុម

ប្រឹក្សាទាំងនេះ ត្រូវបានធ្វើឡើងជាទៀងទាត់ស្របតាមអាណត្តិនីមួយៗដែលកំណត់ក្នុងច្បាប់។ កិច្ចការនេះចាត់ទុកថាជាសមិទ្ធផលជាប្រវត្តិសាស្ត្រសម្រាប់កម្ពុជា ក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងជាការចាក់ឫសគល់ដ៏រឹងមាំនៃគោលការណ៍ប្រជាធិបតេយ្យ និងវិមជ្ឈការក្នុងប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា បន្ទាប់ពីកម្ពុជាទទួលបានសុខសន្តិភាពពេញលេញក្រោម **គោលនយោបាយឈ្នះ-ឈ្នះ** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

- ការរៀបចំឡើងវិញជាបណ្តើរៗនូវរចនាសម្ព័ន្ធ មុខងារ ធនធានតាមគោលការណ៍នៃរដ្ឋបាលឯកភាព និងទៅតាមចរិតលក្ខណៈនៃប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ព្រមទាំងការរៀបចំនូវនីតិវិធីអនុវត្តការងារ រួមមាន នីតិវិធីរៀបចំកិច្ចប្រជុំ និងការធ្វើសេចក្តីសម្រេចចិត្ត នីតិវិធីនៃការរៀបចំវេទិកាពិគ្រោះយោបល់សាធារណៈរបស់ក្រុមប្រឹក្សា និងនីតិវិធីនៃការគ្រប់គ្រងកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ ដើម្បីបង្កលក្ខណៈឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌។

### ៣. ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដើម្បីជានាដល់ការផ្តល់សិទ្ធិអំណាចពេញលេញដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួនស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន (សិទ្ធិអំណាចទាំងនេះរួមមានតាំងពីការរៀបចំផែនការបុគ្គលិក ការជ្រើសរើសបុគ្គលិក ការផ្ទេរ ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិរហូតដល់ការចូលនិវត្តន៍)។ មកទល់ពេលនេះ បុគ្គលិកចំនួនប្រមាណជាង ៤០.០០០នាក់ ដែលរួមមានទាំងបុគ្គលិកផ្នែករដ្ឋបាល និងបុគ្គលិកជំនាញត្រូវបានផ្ទេរទៅស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិកទាំងនោះលើការទទួលខុសត្រូវ តួនាទី ភារកិច្ច និងនីតិវិធីអនុវត្តការងារក៏ត្រូវបានផ្តល់តាមរយៈវគ្គបណ្តុះបណ្តាលខ្លីៗ សិក្ខាសាលា និងការហ្វឹកហាត់ការងារជាក់ស្តែង។ ទន្ទឹមនោះ សាលាជាតិរដ្ឋបាលមូលដ្ឋានក៏ត្រូវបានបង្កើតឡើង និងកំពុងដំណើរការជាជំហានៗ ដើម្បីផ្តល់សេវាអភិវឌ្ឍសមត្ថភាពដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

### ៤. ការផ្ទេរមុខងារ និងការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីបំពេញមុខងារជាអាណត្តិទូទៅ និងមុខងារជាកាតព្វកិច្ច។ មុខងារជាអាណត្តិទូទៅត្រូវបានផ្តល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយច្បាប់រៀបចំអង្គការពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍនៅមូលដ្ឋានក្នុងដែនសមត្ថកិច្ច

របស់ខ្លួន។ មុខងារជាកាតព្វកិច្ចត្រូវបានផ្តល់ជូនតាមរយៈការផ្ទេរមុខងារពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអាជ្ញាធរសាធារណៈនានា ដែលមកទល់បច្ចុប្បន្ននេះ មានមុខងារក្នុងវិស័យសង្គមកិច្ច និងសុខាភិបាលត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងមុខងារចំនួន៥៥ក្នុងវិស័យចំនួន ២០ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងមុខងារមួយចំនួនពាក់ព័ន្ធនឹងមត្តេយ្យសិក្សាសហគមន៍ ការងារអេប់រំបរិស្ថាន និងសង្គមកិច្ចត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលឃុំ សង្កាត់ ដើម្បីបង្កិតការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឱ្យកៀកជិតប្រជាពលរដ្ឋនៅមូលដ្ឋាន និងឆ្លើយតបបានទាន់ពេល វេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

ជាមួយគ្នានេះ យន្តការច្រកចេញចូលតែមួយត្រូវបានបង្កើតឡើងនៅគ្រប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីបង្កលក្ខណៈងាយស្រួល និងឆាប់រហ័សក្នុងការផ្តល់សេវារដ្ឋបាលនានាជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

តាមរយៈការអនុវត្តនូវមុខងារទាំងនេះ រដ្ឋបាលថ្នាក់ក្រោមជាតិបាន និងកំពុងផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយចំនួនប្រមាណជាង៦០០ប្រភេទសេវាលើវិស័យ និងកិច្ចការអាទិភាពនានា ព្រមទាំងបានរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងគម្រោងផ្តល់សេវាសង្គមនានាប្រមាណជាង២.០០០គម្រោងក្នុងមួយឆ្នាំៗ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅតាមមូលដ្ឋាន ដែលជាការរួមចំណែកក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែមានភាពល្អប្រសើរឡើង។

### ៤. វិមជ្ឈការហិរញ្ញវត្ថុ

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមគោលការណ៍វិមជ្ឈការហិរញ្ញវត្ថុត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដែលរួមមានដូចជា ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក។ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនេះ បានផ្តល់ឆន្ទានុសិទ្ធិដល់រដ្ឋបាលទាំងនេះក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ ផ្អែកតាមគោលការណ៍ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់មូលដ្ឋាននីមួយៗ។

ប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានបង្កើតឡើង ដែលរួមមាន ប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុគ្មានភ្ជាប់លក្ខខណ្ឌ ដូចជា មូលនិធិឃុំ សង្កាត់ មូលនិធិក្រុង ស្រុក និងប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ដូចជា ប្រព័ន្ធផ្ទេរមូលនិធិវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ ព្រមទាំងប្រព័ន្ធចែករំលែកចំណូលសារពើពន្ធរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងក្របខ័ណ្ឌនៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុរហូតមកដល់ឆ្នាំ២០២០នេះ រាជរដ្ឋាភិបាល

បានផ្ទេរថវិការជួសរុបចំនួនប្រមាណ៣.៨០០លានដុល្លារ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ដើម្បីផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**៦. ការរៀបចំប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ប្រព័ន្ធកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានដូចជា ផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅគ្រប់ប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាប្រព័ន្ធកសាងផែនការដែលមានលក្ខណៈបើកចំហ មានតម្លាភាព មានការពិគ្រោះយោបល់ មានការចូលរួម និងស្របទៅតាមចរិតលក្ខណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីធានាដល់ការប្រើប្រាស់ធនធាននានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ ប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌។

**៧. ការពង្រឹងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

យន្តការគណនេយ្យភាពតាមបែបប្រជាធិតេយ្យត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត រួមមានដូចជា ទី១-ការបង្កើតការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ដើម្បីទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ានានាក្រៅប្រព័ន្ធតុលាការពាក់ព័ន្ធនឹងការបំពេញមុខងារ និងការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទី២-ការបង្កើតយន្តការសម្រុះសម្រួលនិងដោះស្រាយវិវាទនៅមូលដ្ឋានរវាងប្រជាពលរដ្ឋនិងប្រជាពលរដ្ឋ ដើម្បីផ្តល់សេវាពិគ្រោះយោបល់ផ្នែកផ្លូវច្បាប់ និងការជួយសម្រុះសម្រួលដោះស្រាយវិវាទនានានៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ និងទី៣-ការបង្កើតក្របខ័ណ្ឌការងារគណនេយ្យភាពសង្គមក្នុងភាពជាដៃគូជាមួយអង្គការសង្គម ស៊ីវិល ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យប្រជាពលរដ្ឋទទួលបាននូវព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកាឃុំ សង្កាត់ និងអង្គភាពជំនាញនានានៅតាមមូលដ្ឋាន ព្រមទាំងដើម្បីបង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋក្នុងការចូលរួមតាមដាន ត្រួតពិនិត្យ និងផ្តល់យោបល់កែលម្អលើការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការផ្តល់សេវារបស់អង្គភាពផ្តល់សេវាសាធារណៈ នៅមូលដ្ឋានមួយចំនួនផងដែរ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !**

ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលធំៗដូចបានគូសបញ្ជាក់ខាងលើ ក៏នៅមានបញ្ហាប្រឈមជាគន្លឹះៗមួយចំនួនដែលត្រូវបន្តដោះស្រាយ ដូចខាងក្រោម៖

**ទី១.បញ្ហាប្រឈមពាក់ព័ន្ធនឹងការរៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ៖**

ទោះបីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំឡើងវិញ

និងកែសម្រួលជាបណ្តើរៗនាពេលកន្លងមកក៏ដោយ ក៏របនាសម្ព័ន្ធ និងប្រព័ន្ធទាំងនេះនៅមិនទាន់មានលក្ខណៈសមស្របទាំងស្រុងទៅតាមចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដែលមានលក្ខណៈជាទីក្រុងធំ តំបន់ទីប្រជុំជន និងតំបន់ជនបទ ព្រមទាំងមិនទាន់ស្របទៅតាមលក្ខណៈភូមិសាស្ត្រ ប្រជាសាស្ត្រ និងសក្តានុពលសេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលមានលក្ខណៈខុសៗគ្នានៅឡើយ។

**ទី២.បញ្ហាប្រឈមពាក់ព័ន្ធនឹងការផ្ទេរមុខងារ៖**

នាពេលកន្លងមក បើទោះមានការផ្ទេរមុខងារមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិហើយក៏ដោយ ក៏ការបែងចែកសិទ្ធិ អំណាច តួនាទី ភារកិច្ច និងការទទួលខុសត្រូវលើការអនុវត្តមុខងារផ្តល់សេវាចាំបាច់មួយចំនួនរវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានភាពមិនទាន់ច្បាស់លាស់ ព្រមទាំងពុំទាន់ សមស្របទៅនឹងគោលការណ៍វិមជ្ឈការ ក្នុងការបង្វិតសេវាសាធារណៈដែលជាតម្រូវការចាំបាច់នានាឱ្យទៅកៀកជិតជាមួយប្រជាពលរដ្ឋនោះឡើយ។ ទន្ទឹមគ្នានេះ ការផ្ទេរធនធានចាំបាច់នានា រួមមាន ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ ឧបករណ៍ សម្ភារៈបរិក្ខា និងមធ្យោបាយនានាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏នៅមានភាពយឺតយ៉ាវ និងមិនច្បាស់លាស់ ដែលប្រការទាំងនេះបានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់មានលទ្ធភាពពេញលេញក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារទាំងនោះប្រកបដោយប្រសិទ្ធភាពខ្ពស់នៅឡើយ។

**ទី៣.បញ្ហាពាក់ព័ន្ធនឹងការធ្វើគណនេយ្យភាពចំពោះប្រជាពលរដ្ឋ៖**

ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួននៅពុំទាន់អាចបំពេញតួនាទីឱ្យបានពេញលេញជាតំណាងប្រជាពលរដ្ឋ ក្នុងការឆ្លើយតបទៅនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយសារការខ្វះធនធាន និងសមត្ថភាពនៅមានកម្រិត។ ទន្ទឹមគ្នានេះ ទោះបីមានការរៀបចំយន្តការជាច្រើន ដើម្បីធានាដល់ការចូលរួមមតិយោបល់ និងការតាមដានត្រួតពិនិត្យរបស់ប្រជាពលរដ្ឋទៅលើការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា និងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ ក៏ប្រជាពលរដ្ឋភាគច្រើននៅតាមមូលដ្ឋាននៅពុំទាន់យល់ដឹងច្បាស់អំពីសិទ្ធិរបស់ខ្លួន ក្នុងការជំរុញឱ្យក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានគណនេយ្យភាពចំពោះខ្លួន ដែលជាម្ចាស់ឆ្នោតនៅឡើយ។

**ទី៤.បញ្ហាពាក់ព័ន្ធនឹងភាពជាដៃគូជាមួយសង្គមស៊ីវិល និងផ្នែកឯកជន៖**

នាពេលកន្លងមក ការចូលរួមរបស់អង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ តាមរយៈការចូលរួមក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយ ការកសាងផែនការ ការអនុវត្តគម្រោងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ការអភិវឌ្ឍសមត្ថភាព និងជាពិសេស ការអនុវត្តការងារគណនេយ្យភាពសង្គម។ ក៏ប៉ុន្តែការចូលរួមទាំងនេះ នៅពុំទាន់មានភាពពេញលេញ និងមាននិរន្តរភាពនៅឡើយ។ អាស្រ័យហេតុនេះ ចាំបាច់ត្រូវបន្តលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយសង្គមស៊ីវិល និងវិស័យឯកជននានាក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ព្រមទាំងរួមចំណែកលើកកម្ពស់អភិបាលកិច្ចល្អប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិបន្ថែមទៀត។

**ទី៩.បញ្ហាពាក់ព័ន្ធប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា៖**

បច្ចុប្បន្ននេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងពិភពលោកកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័សដែលបាន និងកំពុងប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងប្រព័ន្ធ គ្រប់គ្រងការងារ ការចែករំលែកព័ត៌មាន និងការប្រាស្រ័យទាក់ទងជាសាធារណៈ។ ទោះយ៉ាង នេះក្តី បច្ចុប្បន្ននេះ រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជាបំពេញការងារភាគច្រើននៅតែផ្អែកលើប្រព័ន្ធ រដ្ឋបាលដែលប្រើប្រាស់ក្រដាសស្នាម និងធ្វើការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋដោយការជួបមុខគ្នាដោយផ្ទាល់ដែលជាហេតុធ្វើឱ្យការផ្តល់សេវា និងការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនៅមានភាពយឺតយ៉ាវ និងមានការលំបាក។ ប្រការនេះ ចាំបាច់ត្រូវជំរុញការរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យានៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី** !

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំដំបូងនឹងត្រូវបញ្ចប់នៅចុងឆ្នាំ២០២០នេះ។ ផ្អែកលើសមិទ្ធផល មេរៀន បទពិសោធន៍នាពេលកន្លងមក និងបញ្ហាប្រឈមនានាដែលត្រូវបន្តដោះស្រាយ ព្រមទាំងក្នុងគោលបំណងបន្តជំរុញការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែស៊ីជម្រៅ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ជាពិសេស ដើម្បីចូលរួមចំណែកសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយប្រទេសកម្ពុជាឱ្យក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ រាជរដ្ឋាភិបាលចាំបាច់ត្រូវរៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីជាតិដំណាក់កាលទី២សម្រាប់រយៈពេល១០ឆ្នាំបន្ថែមទៀត គឺចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០។

ជាការពិតណាស់ ដើម្បីធានាដល់ការសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់រយៈពេល១០ឆ្នាំខាងមុខនេះ យើងចាំបាច់ត្រូវបន្តធ្វើកំណែទម្រង់រចនាសម្ព័ន្ធរដ្ឋបាលសាធារណៈឱ្យកាន់តែស៊ីជម្រៅ និងមានប្រសិទ្ធភាព ដូចនេះ ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈ គឺជាកត្តាដ៏មានសារៈសំខាន់មួយក្នុងការចូលរួមចំណែកសម្រេចបាននូវចក្ខុវិស័យនេះ។ ក្នុងន័យនេះ កម្មវិធីជាតិដំណាក់កាលទី២នឹងត្រូវកំណត់ឱ្យបានច្បាស់លាស់នូវការទទួលខុសត្រូវរវាងក្រសួងស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ

នីមួយៗ ដើម្បីចៀសវាងឱ្យបាននូវភាពមិនច្បាស់លាស់នៃការទទួលខុសត្រូវ និងភាពត្រួតស៊ីគ្នានៃការទទួលខុសត្រូវរវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

ជារួម ក្នុងអំឡុងពេល១០ឆ្នាំខាងមុខនេះ យើងត្រូវធ្វើទំនើបកម្មរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈ រួមជាមួយនឹងការកំណត់ឱ្យបានច្បាស់លាស់នូវសិទ្ធិអំណាច មុខងារ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់។

ពាក់ព័ន្ធនឹងកិច្ចការទាំងនេះ គ.ជ.អ.ប. បានចាត់ចែងឱ្យមានការសិក្សា និងរៀបចំសេចក្តីព្រាងឯកសារទស្សនទានសម្រាប់ជាមូលដ្ឋានតម្រង់ទិសដល់ការរៀបចំតាក់តែងកម្មវិធីជាតិសម្រាប់រយៈពេល១០ឆ្នាំដំណាក់កាលទី២ ពីឆ្នាំ២០២១ដល់ឆ្នាំ២០៣០។ សេចក្តីព្រាងឯកសារទស្សនទាននេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើកម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល យុទ្ធសាស្ត្រអភិវឌ្ឍជាតិ គោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់រៀបចំអង្គការ និងបញ្ហាប្រឈម នានាដែលត្រូវដោះស្រាយ ព្រមទាំងមេរៀន បទពិសោធន៍នៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅបណ្តាប្រទេសមួយចំនួនក្នុងតំបន់ និងក្នុងពិភពលោក។ យើងបានប្រើប្រាស់ពេលវេលាជាង៦ខែ ដើម្បីសិក្សារៀបចំឯកសារទស្សនទាននេះ ដោយមានការពិភាក្សា និងពិគ្រោះយោបល់ជាមួយមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធមួយចំនួន។

ដើម្បីឱ្យឯកសារទស្សនទាននេះ ទទួលបាននូវធាតុចូលបន្ថែមទៀត ជាពិសេស ការមូលមតិឯកភាពគ្នាលើចក្ខុវិស័យ និងគោលដៅជាយុទ្ធសាស្ត្រសំខាន់ៗសម្រាប់ការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ រាជរដ្ឋាភិបាលបានសម្រេចអនុញ្ញាតឱ្យរៀបចំសិក្ខាសាលា ជាតិនាពេលនេះ ដែលឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមគូសបញ្ជាក់ជូននូវចក្ខុវិស័យជាគន្លឹះៗមួយចំនួន សម្រាប់រយៈពេល១០ឆ្នាំខាងមុខដូចខាងក្រោម៖

**ទីមួយ៖ ការពិនិត្យឡើងវិញនូវមុខងារ និងរចនាសម្ព័ន្ធគ្រប់គ្រងនៃរដ្ឋបាលសាធារណៈ**

ការបែងចែកសិទ្ធិ អំណាច មុខងារ និងការទទួលខុសត្រូវរវាងរដ្ឋបាលតាមថ្នាក់នីមួយៗត្រូវផ្អែកលើគោលការណ៍ដែលកំណត់ថា សេវាសាធារណៈនានាត្រូវផ្តល់ដោយរដ្ឋបាលថ្នាក់ណាដែលអាចមានប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច និងសង្គមខ្ពស់បំផុត ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋតាមមូលដ្ឋានបានយ៉ាងល្អប្រសើរ និងឆាប់រហ័សជាងគេ។

ផ្អែកលើគោលការណ៍នេះ រចនាសម្ព័ន្ធ មុខងារ ការទទួលខុសត្រូវ និងប្រព័ន្ធទំនាក់ទំនងអន្តរស្ថាប័នរវាងរដ្ឋបាលតាមថ្នាក់នីមួយៗនឹងត្រូវពិនិត្យ និងកែសម្រួលឡើងវិញដូចតទៅ៖

- **ក្រសួង ស្ថាប័នថ្នាក់ជាតិ៖** នឹងមានមុខងារស្នូលសំខាន់ៗមួយចំនួនដូចជា ១). ការសិក្សា

ស្រាវជ្រាវដើម្បីជំរុញការអភិវឌ្ឍ និងនវានុវត្តន៍តាមវិស័យជំនាញនីមួយៗ ២). ការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត បទដ្ឋានបច្ចេកទេសសម្រាប់កំណត់ស្តង់ដាសេវានានា ៣). គាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង៤). ការអនុវត្តមុខងារជាយុទ្ធសាស្ត្រធំៗមួយចំនួន។

- **រដ្ឋបាលរាជធានី៖** រាជធានីភ្នំពេញនឹងរៀបចំឱ្យក្លាយទៅជារដ្ឋបាលទីក្រុង**មេត្រូប៉ូលីតែន** (Metropolitan) ដែលមានប្រព័ន្ធគ្រប់គ្រងដោយឡែកពីរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុងដទៃទៀត។ ប្រព័ន្ធគ្រប់គ្រងរាជធានីភ្នំពេញ (ទីក្រុងមេត្រូប៉ូលីតែន) នឹងត្រូវរៀបចំស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដែលអាចរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគមានលក្ខណៈជាយុទ្ធសាស្ត្រ អាចអនុវត្តគម្រោងវិនិយោគធំៗ ព្រមទាំងអាចសម្របសម្រួលបាននូវការផ្តល់សេវាសាធារណៈនានានៅទូទាំងដែនដីនៃរដ្ឋបាលរាជធានីប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ រចនាសម្ព័ន្ធ មុខងារ សិទ្ធិអំណាច និងរបៀបរបបការងារ ព្រមទាំងខ្សែគណនេយ្យភាពរបស់ទីក្រុងមេត្រូប៉ូលីតែននឹងត្រូវធ្វើការសិក្សាយ៉ាងល្អិតល្អន់ ដោយដកស្រង់នូវមេរៀន បទពិសោធន៍នានា និងផ្អែកលើ បរិបទជាក់ស្តែងរបស់កម្ពុជា នៅក្នុងដំណាក់កាលនៃការអនុវត្តកម្មវិធីជាតិ១០ឆ្នាំខាងមុខនេះ។
- **រដ្ឋបាលខេត្ត៖** នឹងរៀបចំប្រែក្លាយទៅជារដ្ឋបាលដែលមានរចនាសម្ព័ន្ធគ្រប់គ្រង និងចរិតលក្ខណៈជារដ្ឋបាលតំបន់ តាមគោលការណ៍នៃរដ្ឋបាលឯកភាព។ រដ្ឋបាលតំបន់មានមុខងារសំខាន់ៗមួយចំនួនដូចជា ១). បំពេញមុខងារជាតំណាងឱ្យរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នក្នុងការថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងអនុវត្តមុខងារនានាដែលរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នធ្វើប្រតិភូកម្មឱ្យ ២). បំពេញមុខងារនានាពាក់ព័ន្ធនឹងការគាំទ្របច្ចេកទេស ការអភិវឌ្ឍសមត្ថភាព ការសម្របសម្រួល ការត្រួតពិនិត្យនីត្យានុកូលភាព ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋាន និង៣). អនុវត្តមុខងារ ឬគម្រោងក្នុងវិស័យសាធារណៈសំខាន់ៗមួយចំនួនដែលមានលក្ខណៈបច្ចេកទេសខ្ពស់ និងឬមានវិសាលភាពគ្របដណ្តប់លើភូមិសាស្ត្រទូទាំងខេត្តដែលរដ្ឋបាលក្រុង ស្រុកពុំអាចអនុវត្តបាន។
- **រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់៖** នឹងប្រែក្លាយទៅជារដ្ឋបាលមូលដ្ឋានដែលមានស្វ័យភាព និងការទទួលខុសត្រូវជាសំខាន់លើការផ្តល់សេវាសាធារណៈចាំបាច់ជាមូលដ្ឋានដោយផ្ទាល់ជូនប្រជាពលរដ្ឋ។ រដ្ឋបាលមូលដ្ឋានទាំងនេះនឹងត្រូវរៀបចំឱ្យមានរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងផ្សេងៗគ្នា ស្របតាមសក្តានុពល និងស្ថានភាពនៃតម្រូវការផ្សេងៗគ្នារវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ។ រដ្ឋបាលមូលដ្ឋានទាំងនេះ

នឹងមានមុខងារសំខាន់ៗចំនួន៣គឺ ១). កំណត់តម្រូវការ និងបញ្ហាប្រឈមនានានៅតាមមូលដ្ឋាន តាមរយៈដំណើរការកសាងផែនការដោយមានការចូលរួមដោយផ្ទាល់ពីប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន ២). រៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍន៍មូលដ្ឋាន និងផ្តល់សេវាចាំបាច់ជាមូលដ្ឋាននានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមបទដ្ឋានបច្ចេកទេស និងស្តង់ដាសេវាដែលបានកំណត់ ដើម្បីឆ្លើយបតទៅនឹងតម្រូវការ និងដោះស្រាយបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋដែលមានលក្ខណៈផ្សេងៗគ្នានៅតាមមូលដ្ឋាននីមួយៗ និង៣). រៀបចំ និងអនុវត្តការងារគណនេយ្យភាពជាមួយប្រជាពលរដ្ឋតាមរយៈក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រុមជាតិនីមួយៗ។

**ទីពីរ៖ ការរៀបចំធនធាន និងកិច្ចការពាក់ព័ន្ធចាំបាច់នានា៖**

ជារួម ការពិនិត្យ និងការកែសម្រួលឡើងវិញនូវមុខងារ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈ គឺជាកិច្ចការស្នូលនៃកម្មវិធីជាតិដំណាក់កាលទី២សម្រាប់អនុវត្តរយៈពេល ១០ឆ្នាំខាងមុខ។ កិច្ចការស្នូលទាំងនេះនឹងពាក់ព័ន្ធទៅនឹងតម្រូវការចាំបាច់នៃការពិនិត្យ និងការរៀបចំឡើងវិញនូវច្បាប់ លិខិតបទដ្ឋានគតិយុត្តឱ្យបានច្បាស់លាស់ ការពិនិត្យ និងរៀបចំឡើងវិញនូវធនធានមនុស្ស និងធនធានហិរញ្ញវត្ថុឱ្យបានសមស្របទៅនឹងមុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលសាធារណៈតាមថ្នាក់នីមួយៗ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពជាម្ចាស់ និងមានលទ្ធភាពធ្វើការអភិវឌ្ឍមូលដ្ឋាន និងផ្តល់សេវាសាធារណៈឆ្លើយតបទៅនឹងតម្រូវការ និងដោះស្រាយបញ្ហាប្រឈមនានានៅតាមមូលដ្ឋានរបស់ខ្លួន។

**ទីបី៖ អភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិក៖**

ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈ គឺជាកិច្ចការអាទិភាពមួយដែលយើងត្រូវរៀបចំ និងជំរុញការអនុវត្តនៅគ្រប់កម្រិតថ្នាក់នៃរដ្ឋបាលសាធារណៈរបស់យើង ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈឆ្លើយតបទៅនឹងតម្រូវការ និងការរីកចម្រើនយ៉ាងឆាប់រហ័សនូវបច្ចេកវិទ្យាព័ត៌មានវិទ្យានៅក្នុងប្រទេសកម្ពុជា។ អាស្រ័យហេតុនេះ យើងត្រូវជំរុញការរៀបចំ និងអនុវត្តប្រព័ន្ធអេឡិចត្រូនិកក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិជាបណ្តើរៗលើកិច្ចការសំខាន់នានាដូចជា ទំនាក់ទំនងការងាររវាងរដ្ឋបាលនិងរដ្ឋបាល ទំនាក់ទំនងការងាររវាងរដ្ឋបាលនិងប្រជាពលរដ្ឋ ការផ្តល់សេវាធារណៈ ការផ្សព្វផ្សាយព័ត៌មាន និងការអភិវឌ្ឍសមត្ថភាពជាដើម។

**ទីបួន៖ កិច្ចការអន្តរវិស័យ៖**

កម្មវិធីជាតិដំណាក់កាលទី២នឹងបន្តផ្តោតទៅលើការលើកកម្ពស់ការងារអន្តរវិស័យចាំបាច់នានា រួមមាន ការងារយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ការប្រែប្រួលអាកាសធាតុ និងគ្រោះ

មហន្តរាយ តាមរយៈការបញ្ជ្រាបកិច្ចការអន្តរវិស័យទាំងនេះទៅក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានលទ្ធភាពពេញលេញក្នុងការគ្រប់គ្រងធនធានមនុស្ស ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដោយគ្មានការរើសអើង ការប្រកាន់ជាតិសាសន៍ សាសនា ភេទ ក្រុមជនងាយរងគ្រោះផ្សេងទៀត ព្រមទាំងអាចសិក្សាវាយតម្លៃ និងឆ្លើយតបទៅនឹងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយនានា ដើម្បីជួយគាំទ្រដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងមូលដ្ឋានរបស់ខ្លួន។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី** !

សិក្ខាសាលាជាតិនាថ្ងៃនេះ មានគោលបំណងផ្តល់ឱកាសជូនឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាថ្នាក់ដឹកនាំក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលក្នុងការពិនិត្យ ពិភាក្សា និងពិគ្រោះយោបល់លើចក្ខុវិស័យសម្រាប់កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេល១០ឆ្នាំខាងមុខ ដើម្បីធានាឱ្យប្រជាពលរដ្ឋទទួលបានផលប្រយោជន៍ពីការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម សំដៅចូលរួមចំណែកសម្រេចឱ្យបាននូវគោលបំណងរួមនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិក្នុងការប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

ពាក់ព័ន្ធនឹងចក្ខុវិស័យទាំងនេះ និងផ្អែកលើមេរៀន បទពិសោធន៍នៃការអនុវត្តជាក់ស្តែងនាពេលកន្លងមក ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមគូសបញ្ជាក់ថា យើងចាំបាច់ត្រូវទទួលស្គាល់នូវសារៈសំខាន់នៃភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការផ្តល់សេវាសាធារណៈចាំបាច់ជាមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងដោះស្រាយបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព។

ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរយៈពេល២ទសវត្សរ៍កន្លងមកនេះ រដ្ឋបាលថ្នាក់ក្រោមជាតិបានដើរតួនាទីយ៉ាងសំខាន់ក្នុងការស្តារ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តខ្នាតតូច គម្រោងផ្តល់សេវាសង្គមយ៉ាងច្រើន ព្រមទាំងការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ក្នុងឆ្នាំ២០២០នេះ រដ្ឋបាលថ្នាក់ក្រោមជាតិបានចូលរួមប្រកបដោយភាពម្ចាស់ការក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ដ៏កាចសាហាវ ស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលយ៉ាងមានប្រសិទ្ធភាព និងការចាត់វិធានការ និងកៀរគរការគាំទ្រពីស្ថាប័នពាក់ព័ន្ធនានា ក្នុងការជួយសង្គ្រោះប្រជាពលរដ្ឋពីគ្រោះទឹកជំនន់យ៉ាងទាន់ពេលវេលា

ស្របទៅតាមស្ថានភាព និងតម្រូវការជាក់ស្តែងរបស់មូលដ្ឋាននីមួយៗ។ ក្នុងន័យនេះ យើងមិនត្រូវមានភាពស្នាក់ស្នើរក្នុងការផ្ទេរសិទ្ធិ អំណាច មុខងារ ធនធាន និងការទទួលខុសត្រូវទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង និងមានលក្ខណៈ ផ្សេងៗគ្នានៅតាមមូលដ្ឋាននីមួយៗនោះឡើយ។

ខ្ញុំសង្ឃឹមថា សិក្ខាសាលាជាតិនាថ្ងៃនេះនឹងទទួលបាននូវមតិយោបល់ដែលជាធាតុចូលដ៏មានសារៈសំខាន់ជាច្រើនបន្ថែមទៀតសម្រាប់ការកំណត់នូវចក្ខុវិស័យ និងកិច្ចការជាអាទិភាពនានានៃកម្មវិធីជាតិដំណាក់កាលទី២ ឱ្យកាន់តែមានភាពជាក់លាក់ ច្បាស់លាស់ និងអាចសម្រេចបាននៅក្នុងរយៈពេល១០ឆ្នាំខាងមុខនេះ។

ជាទីបញ្ចប់នេះ ខ្ញុំសូមជូនពរដល់អង្គសិក្ខាសាលាជាតិឱ្យដំណើរការទៅប្រកបដោយលទ្ធផលជាផ្លែផ្កា និងសូមប្រសិទ្ធិពរជូនឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លាងឃ្លាតឡើយ និងសូមប្រកាសបើក**សិក្ខាសាលាជាតិ**ចាប់ពីពេលនេះតទៅ។

**សូមអរគុណ៕**